# ដឹងអំពីសិទ្ធិរបស់អ្នក

**VOTE 2025**

ជាអ្នកបោះឆ្នោតនៅរដ្ឋ *Minnesota* អ្នកមានសិទ្ធិ ជាច្រើន-សូម ស្វែងយល់អំពីសិទ្ធិទាំងនោះ!

## មានពេលឈប់សម្រាកពីការងារដើម្បីបោះឆ្នោត

អ្នកមានសិទ្ធិឈប់សម្រាកពីការងារដើម្បីបោះឆ្នោត នៅពេលណាក៏បានក្នុងអំឡុងរយៈពេលបោះឆ្នោតដោយ អវត្តមាន ឬនៅថ្ងៃបោះឆ្នោតដោយមិនមានការកាត់ ប្រាក់ឈ្នួល ចំនួនថ្ងៃឈប់សម្រាកផ្ទាល់ខ្លួន ឬរយៈពេល វិស្សមកាលរបស់អ្នកនោះទេ។

## បោះឆ្នោតប្រសិនបើឈរតម្រង់ជួរនៅត្រឹម ម៉ោង 8 ល្ងាច

អ្នកមានសិទ្ធិបោះឆ្នោតប្រសិនបើអ្នកឈរតម្រង់ជួរ បោះឆ្នោតនៅក្នុងពេលណាមួយមុនម៉ោង8យប់។

## ចុះឈ្មោះនៅថ្ងៃបោះឆ្នោត

អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត ប្រសិនបើអ្នកអាចបង្ហាញភ័ស្តុតាងអំពីទីកន្លែងរស់នៅ របស់អ្នក។

## ចុះឈ្មោះដោយផ្ទាល់មាត់

អ្នកមានសិទ្ធិបញ្ជាក់ដោយផ្ទាល់មាត់អំពីអត្តសញ្ញាណ របស់អ្នក និងស្នើឱ្យបុគ្គលផ្សេងទៀតចុះហត្ថខាផ្សេង ទៀតចុះហត្ថលេខាជំនួសអ្នក ប្រសិនបើអ្នកមិនអាច ចុះហត្ថលេខាឈ្មោះរបស់អ្នក។

**កាលបរិច្ឆេទឆ្នាំ 2025**

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី*12* ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី*19* ខែកញ្ញា រហូតដល់ថ្ងៃទី*3*ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃ ទី*14* ខែតុលា ដើម្បីសន្សំ សំចៃពេលវេលានៅថ្ងៃ បោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី*4* ខែវិច្ឆិកា

## ស្នើសុំជំនួយ

អ្នកមានសិទ្ធិស្នើសុំជំនួយពីអ្នកដទៃ លើកលែងតែ ភ្នាក់ងារនៃនិយោជក ឬសហជីព របស់អ្នក

## យកកូនទៅស្ថានីយបោះឆ្នោត

អ្នកមានសិទ្ធិនាំកូនរបស់អ្នកទៅបោះឆ្នោត។

តទៅទំព័រក្រោយ...

ការិយាល័យលេខាធិការរដ្ឋ *Minnesota*
*mnvotes.gov • 1-877-600-VOTE*

# ដឹងអំពីសិទ្ធិរបស់អ្នក

VOTE 2025

.... តពីទំព័រមុខ

## សូមបោះឆ្នោត ប្រសិនបើបច្ចុប្បន្នអ្នកមិនជាប់ពន្ធនាគារពីបទឧក្រិដ្ឋទេ

ប្រសិនបើអ្នកធ្លាប់ជាប់ទោសពីបទឧក្រិដ្ឋ អ្នកអាចបោះឆ្នោតបាន ប្រសិនបើបច្ចុប្បន្ន អ្នកមិនជាប់ពន្ធនាគារពីបទឧក្រិដ្ឋទេ។

## បោះឆ្នោតប្រសិនបើស្ថិតនៅក្រោមការឃ្លាំមើល

អ្នកអាចបោះឆ្នោតនៅពេលស្ថិតក្រោមការឃ្លាំមើលបានលុះត្រាតែចៅក្រមមិនបាន លុបចោលសិទ្ធិបោះឆ្នោតរបស់អ្នក។

## បោះឆ្នោតដោយមិនរង ឥទ្ធិពលពីនរណាម្នាក់

អ្នកមានសិទ្ធិបោះឆ្នោតដោយពុំមាននរណាម្នាក់នៅ កន្លែងបោះឆ្នោតព្យាយាមប្រើ ឥទ្ធិពលមកលើការ បោះឆ្នោតរបស់អ្នក។

## ប្តូរសន្លឹកឆ្នោតថ្មី

អ្នកមានសិទ្ធិប្តូរសន្លឹកឆ្នោតថ្មីប្រសិនបើអ្នកគូសសន្លឹក ឆ្នោតដោយច្រឡំមុនពេលអ្នក ដាក់សន្លឹកឆ្នោតទៅក្នុង ហិបឆ្នោត។

## ដាក់ពាក្យប្តឹង

អ្នកមានសិទ្ធិដាក់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅ ទីកន្លែងបោះឆ្នោតរបស់អ្នក ប្រសិនបើអ្នកមិនពេញចិត្ត ចំពោះការរៀបចំដំណើរការបោះឆ្នោត។

## ដាក់សន្លឹកឆ្នោតគំរូតាមខ្លួន

អ្នកមានសិទ្ធិយកសន្លឹកឆ្នោតគំរូចូលក្នុងកន្លែងគូស សន្លឹកឆ្នោត។

## ដាក់ឯកសារសិទ្ធិអ្នកបោះឆ្នោតតាមខ្លួន

អ្នកមានសិទ្ធិយកឯកសារសិទ្ធិអ្នកបោះឆ្នោតចូលក្នុង កន្លែងគូសសន្លឹកឆ្នោត។

ការិយាល័យលេខាធិការរដ្ឋ *Minnesota*

*mnvotes.gov • 1-877-600-VOTE*